ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ ៤៣៦ ប្រ.ក បស្ថ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០០៩

# ប្រកាស

## ស្តីពី

## ប្រតិភូកម្មអំណាចក្នុងការចេញលិខិតសម្រេចក្នុងនាមក្រសួង ចំពោះគំរោងវិនិយោគ ជូនមន្ទីរបរិស្ថានខេត្ត-ក្រុង

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស / រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃ ទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៥-១៦ ១៧ ១៨-១៩ ២០-២១ ២២-២៣ ២៤-២៥ ២៦-២៧ ២៨-២៩ ៣០ ៣១ ៣២ ៣៣ ៣៤ ៣៥ ៣៦ ៣៧ ៣៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពី[illegible] គណៈកម្មការវិនិយោគ រាជធានី-ខេត្ត ក្រុង ។

# សំរេច

ប្រការ ១- មន្ទីរបរិស្ថានខេត្ត-ក្រុង មានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងសំរេចទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ របស់គំរោងដែលស្នើឡើង ជាបុគ្គលឯកជន ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចំរុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ឬក្រសួងស្ថាប័ន ដែលមានទំហំទុនវិនិយោគក្រោមពីរលាន ( ២.០០០.០០០ ) ដុល្លារ សហរដ្ឋអាមេរិក ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ។

ប្រការ ២- មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវតាមដាន ឃ្លាំមើល និងចាត់វិធានការអោយម្ចាស់គំរោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថាន ក្នុងដំណាក់ការសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដែលបានអនុម័តរួច។

ប្រការ ៣- មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវបង្កើតក្រុមការងារជំនាញមួយ ដែលមានសមាសភាព ប្រធាន អនុប្រធានមន្ទីរ ប្រធានការិយាល័យទាំងអស់ និងមន្ត្រីជំនាញ ដើម្បីពិនិត្យ និងផ្តល់យោបល់ លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងដាក់ឆ្លងសុំយោបល់ពីមន្ទីរជំនាញពាក់ព័ន្ធនិងអ្នកពាក់ព័ន្ធឯទៀត។

ប្រការ ៤- មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ដោយភ្ជាប់នូវឯកសារចំលងសំណុំឯកសារ គំរោងវិនិយោគជូនក្រសួងបរិស្ថាន នៅពេលដែលខ្លួនបានទទួលសំណុំឯកសារគំរោងវិនិយោគ ដែលត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយដែលបានទទួលការអនុញ្ញាតិជាគោលការណ៍ពីអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ។

ប្រការ ៥- មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ជូនក្រសួងបរិស្ថាន អំពីសកម្មភាពដែលបានអនុវត្តរបស់ខ្លួនទៅតាមករណីនីមួយៗ ដោយភ្ជាប់នូវឯកសារចម្លងនៃសំណុំលិខិតទាក់ទងនឹងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោង ឬផែនការគ្រប់គ្រងបរិស្ថាន ។

ប្រការ ៦- មន្ទីរបរិស្ថានខេត្ត-ក្រុង មានសិទ្ធិអនុវត្តវិធានការច្បាប់ ចំពោះបទល្មើសរបស់ម្ចាស់គំរោងដែលបានអនុម័តរួច ហើយបានកំពុងដំណើរការ ដែលមានទឹកប្រាក់វិនិយោគក្រោមពីរលាន (២.០០០.០០០ ) ដុល្លារអាមេរិក ដែលល្មើសនឹងបទប្បញ្ញត្តិណាមួយនៃអនុក្រឹត្យ លេខ៧២ អនក្រ-បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

ប្រការ ៧៖ ក្នុងករណីដែលម្ចាស់គំរោងបានប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងប្រការ៦ ហើយដែលមន្ទីរបរិស្ថានខេត្ត-ក្រុង ពុំមានលទ្ធភាព ឬ សមត្ថភាពគ្រប់គ្រាន់ធ្វើការសន្និដ្ឋាន ចំពោះបទល្មើសទាំងនោះ ត្រូវរាយការណ៍ និងបញ្ជូនមកក្រសួងជាបន្ទាន់ដើម្បីសុំយោបល់ ។

ប្រការ ៨៖ មន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវអនុវត្តអោយបាន ត្រឹមត្រូវតាមខ្លឹមសារអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពី កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

ប្រការ ៩៖ ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងការអនុវត្តការងារដែលបានទទួលប្រតិភូកម្មអំណាច ដូចបានចែងក្នុងប្រកាសនេះ ។

ប្រការ ១០៖ នាយកដ្ឋានជំនាញរបស់ក្រសួង ត្រូវចាត់តាំងមន្ត្រីជំនាញចុះជួយកសាង និងពង្រឹងសមត្ថភាពជំនាញដល់មន្ទីរបរិស្ថានខេត្ត-ក្រុង ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនអោយបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ។

ប្រការ ១១៖ នាយកដ្ឋានជំនាញរបស់ក្រសួងត្រូវចាត់តាំងក្រុមជំនាញចុះធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើសកម្មភាពអនុវត្តគំរោងនៅតាមខេត្ត-ក្រុង ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចការពារបរិស្ថាន ។

ប្រការ ១២៖ អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការ ប្រធានគ្រប់នាយកដ្ឋាន ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

មុក_ម៉ារ៉េត
បណ្ឌិត.ជីវវិទ្យា

**ចម្លងជូន:**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ការប្រគល់សិទ្ធិជូនមន្ទីរបរិស្ថានខេត្ត-ក្រុង ក្នុងការសំរេចចំពោះគំរោង
## ដែលមានទុនវិនិយោគក្រោមពីរលានដុល្លារអាមេរិក

### តារាងឧបសម្ព័ន្ធដែលថ្នាក់ខេត្ត-ក្រុងត្រូវអនុវត្ត
### ចំណាត់ថ្នាក់គំរោងឱ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

| ល.រ | ប្រភេទអាជីវកម្ម | ទំហំ |
|---|---|---|
| ១ | **វិស័យឧស្សាហកម្ម** | |
| ១.១ | មូលដ្ឋានកែច្នៃម្ហូបអាហារ និងគ្រឿងកំប៉ុង | ≥ ៥០០ តោន/ឆ្នាំ |
| ១.២ | មូលដ្ឋានផលិតភេសជ្ជៈ - ទឹកផ្លែឈើគ្រប់ប្រភេទ | ≥ ១.៥០០ លីត្រ/ថ្ងៃ |
| ១.៣ | មូលដ្ឋានផលិតដំណាប់ផ្លែឈើ | ≥ ៥០០ តោន/ឆ្នាំ |
| ១.៤ | មូលដ្ឋានផលិតទឹកក្រូច | គ្រប់ទំហំ |
| ១.៥ | មូលដ្ឋានផលិតស្រា | គ្រប់ទំហំ |
| ១.៦ | មូលដ្ឋានផលិតស្រាបៀរ - អាល់កុល | គ្រប់ទំហំ |
| ១.៧ | មូលដ្ឋានផលិតទឹកស្អាត | ≥ ១០.០០០ នាក់ប្រើប្រាស់ |
| ១.៨ | មូលដ្ឋានផលិតជាវី | ≥ ១០.០០០ កញ្ចប់/ថ្ងៃ |
| ១.៩ | មូលដ្ឋានផលិត កែច្នៃសន្លឹកថ្នាំជក់ | ≥ ៣៥០ តោន/ឆ្នាំ |
| ១.១០ | មូលដ្ឋានផលិតស្ករស | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១១ | មូលដ្ឋានកិនស្រូវ និងគ្រាប់ធញ្ញជាតិ | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១២ | មូលដ្ឋានផលិតទឹកត្រី - ស៊ីអ៊ីវ - សៀង - ម្ទេស - ប៉េងប៉ោះ | ≥ ៥០០.០០០ លីត្រ/ឆ្នាំ |
| ១.១៣ | រោងចក្រតម្បាញ - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.១៤ | រោងចក្រកាត់ដេរមាន : បោកគក់ - បោះពុម្ព - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.១៥ | រោងចក្រសំលាប់ស្បែក - កែច្នៃស្បែក - ធ្វើការស្បែកគោក្របី | គ្រប់ទំហំ |
| ១.១៦ | រោងចក្រផលិតអេប៉ុង - កៅស៊ូទូស | គ្រប់ទំហំ |
| ១.១៧ | រោងចក្រក្ដារបន្ទះ | ≥ ១០០.០០០ [illegible] |
| ១.១៨ | មូលដ្ឋានផលិតគ្រឿងសង្ហារិម | ១[illegible] |

| | | |
|---|---|---|
| ១.១៩ | រោងចក្រអារឈើ | ≥ ៥០.០០០ម$^3$ /ឆ្នាំឈើមូល |
| ១.២០ | រោងចក្រផលិតក្រដាស | គ្រប់ទំហំ |
| ១.២១ | រោងចក្រផលិតម៉ៅក្រដាស និងកែច្នៃក្រដាស | គ្រប់ទំហំ |
| ១.២២ | រោងចក្រកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ | ≥ ៥០០ តោន/ឆ្នាំ |
| ១.២៣ | រោងចក្រកៅស៊ូក្រែប | ≥ ១.០០០ តោន/ឆ្នាំ |
| ១.២៤ | រោងចក្រផលិតអាគុយ និងថ្មពិល | គ្រប់ទំហំ |
| ១.២៥ | រោងចក្រគីមី | គ្រប់ទំហំ |
| ១.២៦ | រោងចក្រផលិតជីគីមី | ≥ ១០.០០០ តោន/ឆ្នាំ |
| ១.២៧ | រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត | គ្រប់ទំហំ |
| ១.២៨ | រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.២៩ | រោងចក្រផលិតម៉ៅសាប៊ូ - សាប៊ូដុំ - សាប៊ូទឹក | គ្រប់ទំហំ |
| ១.៣០ | ស្ថានីយប្រេងឥន្ធនៈ | ≥ ២០.០០០ លីត្រ |
| ១.៣១ | រោងចក្រផលិតកែវ - ឧបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៣២ | មូលដ្ឋានផលិតឥដ្ឋក្បឿង | ≥ ១៥០.០០០ ដុំ/ខែ |
| ១.៣៣ | មូលដ្ឋានផលិតឥដ្ឋក្រាល - ឥដ្ឋការ៉ូ | ≥ ៤០.០០០ ដុំ/ខែ |
| ១.៣៤ | រោងចក្រផលិតថ្មស្មួយ | គ្រប់ទំហំ |
| ១.៣៥ | មូលដ្ឋានផលិតគ្រឿងសំណង់បេតុង | ≥ ៤០០ តោន/ខែ |
| ១.៣៦ | រោងចក្រផលិតខ្លាញ់គោ-ប្រេងម៉ាស៊ីន | គ្រប់ទំហំ |
| ១.៣៧ | រោងចក្រផលិតគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៣៨ | រោងចក្រតំឡើងគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៣៩ | សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា | គ្រប់ទំហំ |
| ១.៤០ | រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ - ដែកគោល - លួសបន្លា - សំណាញ់ | ≥ ៣០០ តោន/ខែ |
| ១.៤១ | រោងចក្រស្លលោហៈគ្រប់ប្រភេទ | គ្រប់ទំហំ |

| | | |
|---|---|---|
| ១.៤២ | រោងចក្រផលិតសំឡី | ≥ ១៥ តោន/ខែ |
| ១.៤៣ | រោងចក្រផលិតចំណីសត្វ | ≥ ១០.០០០ តោន/ឆ្នាំ |
| ២ | **វិស័យកសិកម្ម** | |
| ២.១ | អាជីវកម្មព្រៃគប់ | ≥ ៥០០ ហ.ត ដល់ ៩០០ ហ.ត |
| ២.២ | ផ្ទៃដីដែលមានព្រៃឈើ | ≥ ៥០០ ហ.ត ដល់ ៩០០ ហ.ត |
| ២.៣ | ផ្ទៃដីកសិ-ឧស្សាហកម្ម | ≤៩.០០០ ហ.ត |
| ២.៤ | ប្រព័ន្ធស្រោចស្រព | ≥ ៥.០០០ ហ.ត |
| ២.៥ | ប្រព័ន្ធបង្ហូរទឹក | ≥ ៥.០០០ ហ.ត |
| ២.៦ | ផែនេសាទ | គ្រប់ទំហំ |
| ៣ | **វិស័យទេសចរណ៍** | |
| ៣.១ | តំបន់ទេសចរណ៍ (ក្រៅពីតំបន់ការពារធម្មជាតិ) | ≥ ៥០ ហ.ត |
| ៤ | **ហេដ្ឋារចនាសម្ព័ន្ធ** | |
| ៤.១ | ការអភិវឌ្ឍន៍ទីក្រុង | គ្រប់ទំហំ |
| ៤.២ | ភោជនីយដ្ឋាន | ≥ ៥០០ កៅអី |
| ៤.៣ | សំណង់សណ្ឋាគារ | ≤១០០ បន្ទប់ |